**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

# គោលការណ៍ណែនាំ

# ស្ដីពី

# ការបែងចែកប្រាក់ចំណេញរបស់សហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជា

រៀបចំដោយ៖ គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

**ខែសីហា ឆ្នាំ២០១៦**

**គោលការណ៍ណែនាំស្តីពីការបែងចែកប្រាក់ចំណេញរបស់សហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជា**

បោះពុម្ពផ្សាយ៖ ខែសីហា ឆ្នាំ២០១៦

បោះពុម្ពដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម (MAFF)

គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

អស័យដ្ឋាន៖ # ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់ ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទ៖ (០២៣) ៨៨៣ ៤២៧ ទូរសារ៖ (០២៣) ៨៨៣ ៤២៧

© គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

# មាតិកា


១. គោលបំណងរបស់សហគមន៍កសិកម្ម..........១

២. ការបែងចែកប្រាក់ចំណេញ..........២

២.១. មូលនិធិបម្រុង៖ ជាភាគរយកិច្ច ២០% នៃប្រាក់ចំណេញ..........៤

២.២. មូលនិធិសម្រាប់បណ្ដុះបណ្ដាល៖ ជាភាគរយកិច្ច ៣% នៃប្រាក់ចំណេញ..........៤

២.៣. មូលនិធិសម្រាប់អភិវឌ្ឍន៍សំណង់អគារ (ការិយាល័យ ឃ្លាំង ។ល។) ..........៤

២.៤. ប្រាក់ចំណេញរក្សាទុកសម្រាប់ឆ្នាំក្រោយ ..........៥

២.៥. មូលនិធិលើកទឹកចិត្តសមាជិក និងការកំណត់ប្រាក់ភាគលាភ ..........៥

២.៦. ប្រាក់ឧបត្ថម្ភសម្រាប់សមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ..........៧

## ១. គោលបំណងរបស់សហគមន៍កសិកម្ម

សហគមន៍កសិកម្ម គឺជាសហគ្រាសអាជីវកម្ម ដែលដំណើរការដោយសមាជិកសម្រាប់បម្រើផលប្រយោជន៍ដល់សមាជិក ។

តើសហគមន៍កសិកម្ម គួរផ្តល់ផលប្រយោជន៍ជូនសមាជិកយ៉ាងដូចម្តេច ?

ចម្លើយគឺផ្តល់ផលប្រយោជន៍តាមរយៈមុខរបររបស់សហគមន៍កសិកម្ម ។

សហគមន៍កសិកម្មពហុបំណងដែលចាត់ទុកថាជាសហគមន៍កសិកម្មគំរូនៅប្រទេសកម្ពុជា ក៏ដូចនៅប្រទេសជប៉ុន ថៃ និងនៅបណ្តាប្រទេសនានានៅអាស៊ី ជាទូទៅប្រកប (ក) មុខរបរឥណទាន (ខ) មុខរបរផ្គត់ផ្គង់ (គ) មុខរបរទីផ្សារ និង(ឃ) មុខរបរផ្តល់សេវាប្រើប្រាស់រួមគ្នាដោយឯកឯង ។

ជាទូទៅសហគមន៍កសិកម្មពហុបំណង ផ្តល់ផលប្រយោជន៍ដល់សមាជិកតាមវិធីដូចខាងក្រោម៖

- ផ្តល់ប្រាក់កម្ចីដល់សមាជិកដោយអត្រាការប្រាក់ទាបជាងធនាគារឯកជននិងភ្នាក់ងារមីក្រូហិរញ្ញវត្ថុដែលនៅជិតៗនោះ ហើយនៅពេលដែលអត្រាការប្រាក់ដូចគ្នា សហគមន៍កសិកម្មផ្តល់ប្រាក់កម្ចីឱ្យបានលឿនជាង ។
- ផ្តល់ការប្រាក់នៃប្រាក់បញ្ញើសន្សំខ្ពស់ជាង ។
- ផ្គត់ផ្គង់ជី និងធាតុចូលកសិកម្មផ្សេងទៀតដល់សមាជិកដោយតម្លៃទាបជាងហាងលក់ឯកជនធានាគុណភាព និងបរិមាណជីបានត្រឹមត្រូវ ។
- ទិញផលិតផលកសិកម្មពីសមាជិក ដោយតម្លៃថ្លៃជាងឈ្មួញកណ្តាល ថ្លឹងផលិតផលកសិកម្មដែលទិញពីសមាជិកដោយលក្ខណៈត្រឹមត្រូវ ។
- ផ្តល់សេវាកម្មភ្ជួររាស់ដោយត្រាក់ទ័រ ដោយតម្លៃឈ្នួលទាបជាងឈ្មួញឯកជន ។

ទោះជាយ៉ាងណាក៏ដោយ សហគមន៍កសិកម្មក្នុងប្រទេសកម្ពុជា ភាគច្រើនមានការយល់ដឹងទាបពីគោលគំនិតសហគមន៍កសិកម្ម ("សហគមន៍")។ មន្ត្រីនិងសមាជិកសហគមន៍កសិកម្មស្ទើរតែទាំងអស់មានការយល់ច្រឡំថាគោលបំណងរបស់សហគមន៍កសិកម្ម គឺដើម្បីផ្តល់ "ប្រាក់ភាគលាភ (ភាគលាភធៀបនឹងចំនួនភាគហ៊ុនដែលជាវដោយសមាជិក)" ដែលបានពីផលចំណេញនៃមុខរបរដល់សមាជិក ។

សហគមន៍កសិកម្មទាំងនោះ ជាធម្មតាបានផ្តល់ប្រាក់កម្ចីដល់សមាជិកដោយការប្រាក់ចាប់ពី២% ទៅ៣% ក្នុងមួយខែ (២៤% ទៅ ៣៦% ក្នុងមួយឆ្នាំ) ដែលដូចគ្នាទៅនឹងធនាគារឯកជន ឬខ្ពស់ជាង ។ ជាមួយគ្នានេះដែរ ការប្រាក់នៃប្រាក់បញ្ញើសន្សំរបស់សមាជិក គឺជាធម្មតាចាប់ពី ១% ទៅ ២% ក្នុងមួយខែ (១២% ទៅ២៤% ក្នុងមួយឆ្នាំ) ដែលដូចគ្នាទៅនឹងធនាគារឯកជន ឬទាបជាង ។ ពួកគាត់បានផ្តល់ផលប្រយោជន៍ច្រើនបំផុតដែល

ទទួលបានពីសមតុល្យរវាងការប្រាក់នៃប្រាក់កម្ចីដែលបានទទួល និងការប្រាក់នៃប្រាក់បញ្ញើសន្សំដែលបានចំណាយ ដល់សមាជិកវិញតាមរយៈប្រាក់ភាគលាភ ហើយយល់ថានេះជាគោលបំណងរបស់សហគមន៍កសិកម្ម ។

ការយល់ច្រឡំ គឺបណ្តាលមកពីមន្ត្រី និងសមាជិកសហគមន៍កសិកម្មនៅប្រទេសកម្ពុជាមិនបានទទួលការអប់រំសមស្របអំពីគោលគំនិតពិតរបស់សហគមន៍កសិកម្ម ("សហគមន៍")។ ពួកគាត់គួរតែឈប់យល់ច្រឡំនេះ និងព្យាយាមយល់ឱ្យបានច្បាស់ថា"តើអ្វីជាគោលបំណងពិតរបស់សហគមន៍កសិកម្ម" ។

មន្ត្រីរាជការទទួលបន្ទុកក្នុងការអភិវឌ្ឍន៍សហគមន៍កសិកម្ម ក៏គួរតែយល់ឱ្យកាន់តែហ្មត់ចត់អំពី "សហគមន៍កសិកម្ម ("សហគមន៍") គឺជាអង្គការមួយដែលផ្តល់ផលប្រយោជន៍ដល់សមាជិក តាមរយៈសកម្មភាពអាជីវកម្ម" និង ផ្តល់ការណែនាំសមស្របដល់សហគមន៍កសិកម្មដើម្បីកុំឱ្យពួកគាត់មានការយល់ច្រឡំបន្តទៅទៀត ។

## ២. ការបែងចែកប្រាក់ចំណេញ

ប្រសិនបើ សហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជា ប្រកបមុខរបររបស់ខ្លួនដោយយល់ពីគោលគំនិតពិតរបស់សហគមន៍កសិកម្ម ("សហគមន៍") ពួកគេនឹងកំណត់ការប្រាក់នៃប្រាក់កម្ចីរបស់ពួកគេទាបជាង ឬដូចគ្នានឹងធនាគារដែលនៅជិតខាង ហើយការប្រាក់នៃប្រាក់សន្សំខ្ពស់ជាង ។ ទោះបីជាប្រាក់ចំណេញពីមុខរបរឥណទាន នឹងទាបជាងនាពេលបច្ចុប្បន្ន ប៉ុន្តែពួកគាត់នឹងអាចទទួលបានប្រាក់ចំណេញគ្រប់គ្រាន់ដើម្បីបន្តការគ្រប់គ្រងរបស់ខ្លួន បើពិនិត្យមើលទៅលើស្ថានភាពបច្ចុប្បន្នរបស់ធនាគារនៅប្រទេសកម្ពុជា ។

សន្មតថាក្នុងករណីនេះ តើសហគមន៍កសិកម្មគួរបែងចែកប្រាក់ចំណេញរបស់ខ្លួនយ៉ាងដូចម្តេច?

គោលការណ៍គ្រឹះទី៣ របស់សម្ព័ន្ធសហករណ៍អន្តរជាតិ ចែងដូចខាងក្រោម៖

- សមាជិកទទួលបានភាគលាភមានការកំណត់ បើសិនជាមានប្រាក់ចំណេញ ទៅតាមភាគហ៊ុនដែលពួកគេបានចូលរួមក្នុងលក្ខខណ្ឌជាសមាជិកភាព
- សមាជិកបែងចែកប្រាក់ចំណេញសម្រាប់គោលបំណងខ្លះៗ ឬគោលបំណងទាំងអស់ដូចខាងក្រោម៖
    - អភិវឌ្ឍន៍សហគមន៍របស់ខ្លួន ដែលអាចធ្វើទៅបានដោយការបង្កើតជាមូលនិធិបម្រុង ។
    - ផ្តល់ផលចំណេញដល់សមាជិកតាមសមាមាត្រនៃការធ្វើជំនួញរបស់សមាជិកជាមួយសហគមន៍កសិកម្ម និង
    - គាំទ្រសកម្មភាពផ្សេងៗទៀតដែលអនុម័តដោយសមាជិក ។

- ចំពោះការបែងចែកប្រាក់ចំណេញ ច្បាប់ស្តីពីសហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជាកំណត់ដូចខាងក្រោម៖
    - សហគមន៍កសិកម្មត្រូវបង្កើតមូលនិធិបម្រុងមួយ ដោយដកយកយ៉ាងតិច ២០% ពីប្រាក់ចំណេញសរុបរហូតដល់មូលនិធិបម្រុងនេះស្មើនឹង៥ដងនៃប្រាក់ភាគហ៊ុនសរុប (មាត្រា ៥៧)
    - សហគមន៍កសិកម្មត្រូវបង្កើតមូលនិធិសម្រាប់បណ្តុះបណ្តាលសមាជិក អ្នកគ្រប់គ្រង និងបុគ្គលិកដោយដកយកពីប្រាក់ចំណេញសរុបយ៉ាងតិច ៣% រៀងរាល់ឆ្នាំ(មាត្រា ៥៨)។

ប្រាក់ចំណេញសរុបរបស់សហគមន៍កសិកម្មត្រូវបានបែងចែកតាមគោលការណ៍ដូចខាងក្រោម (មាត្រា ៥៩)៖

- ➢ រក្សាទុកសម្រាប់មូលនិធិបម្រុង និងមូលនិធិបណ្តុះបណ្តាល ឬមូលនិធិផ្សេងទៀតដែលបង្កើតឡើងដោយសហគមន៍កសិកម្ម។
- ➢ ផ្តល់ប្រាក់លើកទឹកចិត្តដល់សមាជិកទៅតាមសមាមាត្រនៃការធ្វើជំនួញរបស់ពួកគេជាមួយសហគមន៍កសិកម្ម
- ➢ បែងចែកភាគលាភដល់សមាជិកតាមចំនួនភាគហ៊ុនដែលសមាជិកកាន់កាប់។

- ចំពោះចំណាយសម្រាប់មន្ត្រីសហគមន៍កសិកម្ម ច្បាប់ចែងដូចខាងក្រោម៖
    - ➢ សមាជិកក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ ពុំមានប្រាក់បំណាច់ឡើយ ប៉ុន្តែមហាសន្និបាតអាចគ្រោងទុកនូវថវិកា សម្រាប់ទូទាត់ចំណាយលើការបំពេញការងារ និងប្រាក់ឧបត្ថម្ភជូនក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យបាន (មាត្រា ៥៣)។
- លើសពីនេះទៀត សហគមន៍កសិកម្ម គឺត្រូវបានអនុញ្ញាតឱ្យរក្សាទុកប្រាក់ចំណេញមួយផ្នែកសម្រាប់ឆ្នាំក្រោយ ។
- គោលគំនិតដែលរៀបរាប់ខាងលើនេះត្រូវបានគេពិចារណា សហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជាគួរបែងចែកប្រាក់ចំណេញរបស់ខ្លួន ទៅតាមលំដាប់នៃអាទិភាព ហើយមន្ត្រីដែលទទួលបន្ទុកក្នុងការអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវផ្តល់ការណែនាំដល់សហគមន៍កសិកម្មឱ្យបែងចែកប្រាក់ចំណេញទៅតាមលំដាប់ដូចខាងក្រោមនេះ៖

(ក) មូលនិធិបម្រុង (ជាកាតព្វកិច្ច ២០% នៃប្រាក់ចំណេញសរុប)

(ខ) មូលនិធិបណ្តុះបណ្តាល (ជាកាតព្វកិច្ច៣% នៃប្រាក់ចំណេញសរុប)

(គ) មូលនិធិសម្រាប់អភិវឌ្ឍន៍សំណង់អគារ (ការិយាល័យ ឃ្លាំង។ល។) (ដោយស្ម័គ្រចិត្ត ហើយ ភាគរយ (ចំនួនទឹកប្រាក់) ត្រូវបានសម្រេចនៅក្នុងមហាសន្និបាត)

(ឃ) ប្រាក់ចំណេញរក្សាទុក (ដោយស្ម័គ្រចិត្ត ហើយភាគរយ "ចំនួនទឹកប្រាក់" ត្រូវបានសម្រេច នៅក្នុងមហាសន្និបាត)

(ង) ប្រាក់លើកទឹកចិត្តសមាជិក (ដោយស្ម័គ្រចិត្ត ហើយភាគរយ "ចំនួនទឹកប្រាក់" ត្រូវបាន សម្រេចនៅក្នុងមហាសន្និបាត)

(ច) ប្រាក់ភាគលាភសម្រាប់សមាជិក (ដោយស្ម័គ្រចិត្ត ហើយភាគរយ "ចំនួនទឹកប្រាក់" ត្រូវបាន សម្រេចនៅក្នុងមហាសន្និបាត ប៉ុន្តែចំនួនប្រាក់ភាគលាភក្នុងមួយភាគហ៊ុនគួរត្រូវបានកំណត់ តិចជាង ១៥% នៃតម្លៃភាគហ៊ុន)

(ឆ) ប្រាក់ឧបត្ថម្ភសម្រាប់សមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ (ដោយ ស្ម័គ្រចិត្ត ហើយភាគរយ "ចំនួនទឹកប្រាក់" ត្រូវបានសម្រេចនៅក្នុងមហាសន្និបាត)។

### ២.១. មូលនិធិបម្រុង

យោងតាមច្បាប់ស្តីពីសហគមន៍កសិកម្ម សហគមន៍កសិកម្មត្រូវបង្កើតមូលនិធិបម្រុងមួយ ដោយដក យកយ៉ាងតិច ២០% ពីប្រាក់ចំណេញសរុបរហូតដល់មូលនិធិបម្រុងនេះមានចំនួន ៥ដង នៃប្រាក់ភាគហ៊ុន សរុប (មាត្រា ៥៧)។

មូលនិធិនេះមិនអាចយកទៅបែងចែកដល់សមាជិកបានឡើយ។ សហគមន៍កសិកម្ម អាចប្រើប្រាស់ មូលនិធិនេះបាន ក្នុងការទូទាត់ការខាតបង់ទៅលើមុខជំនួញរបស់ខ្លួនតែប៉ុណ្ណោះ (មាត្រា ៦១)។

### ២.២. មូលនិធិសម្រាប់បណ្តុះបណ្តាល

យោងតាមច្បាប់ស្តីពីសហគមន៍កសិកម្ម សហគមន៍កសិកម្មគួរបង្កើតមូលនិធិសម្រាប់បណ្តុះបណ្តាល សមាជិក អ្នកគ្រប់គ្រង និងបុគ្គលិក ដោយដកយកពីប្រាក់ចំណេញសរុបយ៉ាងតិច៣% រៀងរាល់ឆ្នាំ ។

មូលនិធិសម្រាប់បណ្តុះបណ្តាល ខុសគ្នាពីមូលនិធិបម្រុង ត្រង់ថាវាអាចដកយក ទៅប្រើប្រាស់ សម្រាប់គោលបំណងទាំងនេះបាន ។

នៅពេលដែលចំនួនទឹកប្រាក់នៃមូលនិធិនេះ កើនឡើងដល់កម្រិតជាក់លាក់មួយ សហគមន៍កសិកម្ម ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់មូលនិធិនេះមួយផ្នែក សម្រាប់សកម្មភាពអប់រំសមាជិក មន្ត្រី និងបុគ្គលិក ដោយមានការឯកភាពពីមហាសន្និបាត ។

## ២.៣. មូលនិធិសម្រាប់អភិវឌ្ឍន៍សំណង់អគារ

(ដកដោយស្ម័គ្រចិត្តហើយភាគរយ (ចំនួនទឹកប្រាក់) ត្រូវសម្រេចដោយមហាសន្និបាត)

នៅពេលសហគមន៍កសិកម្មទទួលបានប្រាក់ចំណេញ ដំបូងសហគមន៍កសិកម្មដកយក ២០% សម្រាប់មូលនិធិបម្រុង និង ៣% សម្រាប់មូលនិធិបណ្តុះបណ្តាលពីប្រាក់ចំណេញសរុប បន្ទាប់មកពិនិត្យថា តើត្រូវបែងចែកប្រាក់ចំណេញដែលនៅសល់យ៉ាងដូចម្តេច (៧៧% នៃប្រាក់ចំណេញសរុប) ។

នៅក្នុងប្រទេសកម្ពុជា សហគមន៍កសិកម្មជាច្រើនមិនមានការិយាល័យ និងឃ្លាំងដែលជាតម្រូវការ (ចាំបាច់)សម្រាប់ការគ្រប់គ្រងសហគមន៍កសិកម្ម ។ ដូច្នេះ មន្ត្រីដែលទទួលបន្ទុកក្នុងការអភិវឌ្ឍន៍សហគមន៍កសិកម្មគួរណែនាំដល់សហគមន៍កសិកម្មទាំងនោះឱ្យបង្កើតមូលនិធិមួយដើម្បីសាងសង់ ការិយាល័យ និង ឃ្លាំង ។ ចំពោះសហគមន៍កសិកម្មណា ដែលមានអាគារទាំងនោះរួចហើយ មន្ត្រីគួរណែនាំអំពីការបង្កើតមូលនិធិមួយទៀត ដើម្បីពង្រឹងមុខរបររបស់ខ្លួន ដូចជា ទិញកុំព្យូទ័រសម្រាប់មុខរបរឥណទាន ឬឡានសម្រាប់មុខរបរទីផ្សារ ឬសាងសង់កន្លែងកែច្នៃផលិតផលកសិកម្ម ។

## ២.៤. ប្រាក់ចំណេញរក្សាទុកសម្រាប់ឆ្នាំក្រោយ

(ដកដោយស្ម័គ្រចិត្ត ហើយភាគរយ (ចំនួនទឹកប្រាក់) ត្រូវសម្រេចដោយមហាសន្និបាត)

បន្ទាប់ពីដកមូលនិធិខាងលើហើយ សហគមន៍កសិកម្មត្រូវពិនិត្យថា តើត្រូវបែងចែកប្រាក់ចំណេញដែលនៅសល់ដូចម្តេចបន្តទៀតរួមមានមូលនិធិបម្រុង មូលនិធិបណ្តុះបណ្តាល និងមូលនិធិសម្រាប់អភិវឌ្ឍន៍សំណង់អាគារ ។

សហគមន៍កសិកម្ម ជាដំបូងដកយកមូលនិធិបម្រុង មូលនិធិបណ្តុះបណ្តាល មូលនិធិសម្រាប់អភិវឌ្ឍន៍សំណង់អាគារ មូលនិធិលើកទឹកចិត្តសមាជិក ប្រាក់ភាគលាភ ។ល។ ពីប្រាក់ចំណេញសរុប បន្ទាប់មករក្សាទុកប្រាក់ចំណេញដែលនៅសល់សម្រាប់ឆ្នាំក្រោយ ។ ប៉ុន្តែ មានសហគមន៍កសិកម្មជាច្រើន នៅក្នុងប្រទេសកម្ពុជាមានការលំបាក ដោយសារកង្វះខាតដើមទុន ហើយមិនអាចជួលបុគ្គលិក អ្នកគ្រប់គ្រង និងអ្នកកត់ត្រាបញ្ជីដែលជាតម្រូវការចាំបាច់ សម្រាប់ការគ្រប់គ្រងសហគមន៍កសិកម្ម ។ សហគមន៍កសិកម្ម គួររក្សាទុកប្រាក់ចំណេញមួយចំណែកដើម្បីជួលបុគ្គលិកចាំបាច់ និងពង្រីកមុខរបររបស់ខ្លួន ។

## ២.៥. មូលនិធិលើកទឹកចិត្តសមាជិក និងការកំណត់ប្រាក់ភាគលាភ

(ដកដោយស្ម័គ្រចិត្ត ហើយភាគរយ (ចំនួនទឹកប្រាក់) ត្រូវសម្រេចដោយមហាសន្និបាត)

ដូចដែលបានពន្យល់ខាងលើ សហគមន៍កសិកម្មត្រូវដកយកមូលនិធិបម្រុង មូលនិធិបណ្តុះបណ្តាល និង មូលនិធិអភិវឌ្ឍន៍សំណង់អគារ ពីប្រាក់ចំណេញសរុប បន្ទាប់មក ពិនិត្យថាតើត្រូវចំណាយប៉ុន្មាន សម្រាប់

មូលនិធិលើកទឹកចិត្តសមាជិក ប្រាក់ភាគលាភ និងប្រាក់ឧបត្ថម្ភសម្រាប់សមាជិកក្រុមប្រឹក្សាភិបាល និង គណៈកម្មាធិការត្រួតពិនិត្យ ។

ចំពោះមូលនិធិលើកទឹកចិត្តសមាជិក និងប្រាក់ភាគលាភជាអាទិភាពគួរត្រូវបានផ្តល់ឱ្យមូលនិធិលើកទឹកចិត្តសមាជិកដោយសារយោងតាមគោលបំណងរបស់សហគមន៍កសិកម្ម "ដើម្បីផ្តល់ផលប្រយោជន៍ដល់សមាជិកតាមរយៈមុខរបររបស់ខ្លួន" និងគោលការណ៍គ្រឹះទី៣ របស់សម្ព័ន្ធសហករណ៍អន្តរជាតិ និង មាត្រា ៥៩ នៃច្បាប់ស្តីពីសហគមន៍កសិកម្មនៅប្រទេសកម្ពុជា ។

មូលនិធិលើកទឹកចិត្តសមាជិក ជាវិធីផ្តល់ប្រាក់បន្ថែម ដោយដកចេញពីប្រាក់ចំណេញរបស់សហគមន៍កសិកម្មដល់សមាជិក ដែលប្រើប្រាស់សេវាកម្មរបស់សហគមន៍កសិកម្មច្រើន ។ ឧទាហរណ៍ សហគមន៍កសិកម្មមួយផ្តល់ប្រាក់លើកទឹកចិត្តដល់សមាជិក តាមចំនួនជីដែលសមាជិកទាំងនោះបានទិញ។ ករណីដែល អត្រាប្រាក់លើកទឹកចិត្តដល់សមាជិក ត្រូវបានសម្រេចយកចំនួន ៣% សហគមន៍កសិកម្មនោះ ចំណាយ ៩ ដុល្លារ (៣០០ ដុល្លារ x ៣%) ដល់សមាជិកដែលបានទិញជីចំនួន ៣០០ ដុល្លារ និង ៣ ដុល្លារ (១០០ ដុល្លារ x ៣%) ដល់សមាជិកដែលបានទិញជីចំនួន ១០០ ដុល្លារ ។ដូច្នេះ សហគមន៍កសិកម្មគួរសម្រេចថាតើមុខរបរណាដែលសហគមន៍កសិកម្មនឹងផ្តល់ប្រាក់លើកទឹកចិត្តដល់សមាជិក ហើយទឹកប្រាក់ចំនួនប៉ុន្មាន មុននឹងសម្រេចចំនួនប្រាក់ភាគលាភ ។

ចំពោះប្រាក់ភាគលាភ អនុលោមតាមគោលការណ៍គ្រឹះទី៣ របស់សម្ព័ន្ធសហករណ៍អន្តរជាតិ ចំនួនប្រាក់ភាគលាភត្រូវមានកំណត់ ។

សហគមន៍កសិកម្មនៅកម្ពុជាស្ទើរតែទាំងអស់ កំពុងគិតថាគោលបំណងរបស់សហគមន៍កសិកម្មគឺដើម្បីផ្តល់ប្រាក់ភាគលាភខ្ពស់ ប៉ុន្តែវាជាការយល់ច្រឡំយ៉ាងធំ ។ ដូចដែលបានរៀបរាប់ពីមុនមក សហគមន៍កសិកម្មគឺ ជាអង្គការដែលផ្តល់ផលប្រយោជន៍ដល់សមាជិកតាមរយៈមុខរបរ ។ សហគមន៍កសិកម្មមិនមែនជាអង្គការ ដែលផ្តល់ផលប្រយោជន៍ដល់សមាជិកតាមរយៈការផ្តល់ប្រាក់ភាគលាភទេ ។ ប្រជាកសិករគួរក្លាយជាសមាជិកដើម្បីប្រើប្រាស់មុខរបររបស់សហគមន៍កសិកម្ម មិនមែនដើម្បីទទួលបានប្រាក់ភាគលាភទេ ។

ទោះជាយ៉ាងណាក៏ដោយ សហគមន៍កសិកម្មត្រូវផ្តល់ប្រាក់ភាគលាភដល់សមាជិកដើម្បីប្រមូលប្រាក់ភាគហ៊ុនពីសមាជិក ។ ប៉ុន្តែ មន្ត្រីរបស់សហគមន៍កសិកម្មទាំងអស់ត្រូវយល់ឱ្យបានច្បាស់ថាការផ្តល់ប្រាក់ភាគលាភគឺមិនមែនជាគោលបំណងពិតរបស់សហគមន៍កសិកម្មទេ ហើយ "ការកំណត់ប្រាក់ភាគលាភ" មានសរសេរនៅក្នុងគោលការណ៍គ្រឹះរបស់សម្ព័ន្ធសហករណ៍អន្តរជាតិ ពួកគាត់ត្រូវធ្វើការអប់រំដល់សមាជិកឱ្យយល់ពីបញ្ហាទាំងនេះ និងប្រឹងប្រែងកាត់បន្ថយភាគរយនៃប្រាក់ភាគលាភ ធៀបតម្លៃភាគហ៊ុនឱ្យនៅតិចជាង ១៥% (ប្រសិនបើតម្លៃភាគហ៊ុនគឺ ១០ ដុល្លារ ប្រាក់ភាគលាភគួរតិចជាង ១,៥ ដុល្លារ) ។

មន្ត្រីដែលទទួលបន្ទុកក្នុងការអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវបង្ហាញពីភាពជាអ្នកដឹកនាំដ៏ខ្លាំងក្លាលើបញ្ហានេះ និងត្រូវពន្យល់ឱ្យបានច្បាស់ ដល់ភ្នាក់ងារអភិវឌ្ឍសហគមន៍ទាំងអស់ដែលកំពុងស្នើសុំបង្កើតសហគមន៍កសិកម្ម ។

ទោះបីជា មន្ត្រីសហគមន៍កសិកម្មភាគច្រើននៅកម្ពុជា កំពុងព្រួយបារម្ភថាសមាជិកជាច្រើន នឹងលាឈប់ពីសហគមន៍កសិកម្ម ប្រសិនបើប្រាក់ភាគលាភមានការកំណត់តិច ។ បើពិចារណាទៅលើអត្រាការប្រាក់ សម្រាប់ប្រាក់បញ្ញើមានកាលកំណត់រយៈពេល១ឆ្នាំ គឺប្រហែល ១០% តើវាបានមកដូចការរំពឹងទុកដែរឬទេ? ក្នុងករណីដែល ប្រជាកសិករចូលរួមជាមួយសហគមន៍កសិកម្ម ដើម្បីទទួលបានប្រាក់ភាគលាភ " ខ្ពស់" គឺពិតជាមិនសមស្របជាសមាជិករបស់សហគមន៍កសិកម្មទេ ដូច្នេះវា មិនប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍កសិកម្មទេ ប្រសិនបើសមាជិកទាំងនោះលាឈប់ពីសហគមន៍កសិកម្ម ។

ប្រសិនបើមានសមាជិកបែបនោះច្រើន វាជាការចាំបាច់ដែលថាសហគមន៍ទាំងនោះ ត្រូវពន្យល់សមាជិកអោយបានយល់ច្បាស់ អំពីគោលបំណងពិតនៃការបង្កើតសហគមន៍កសិកម្មគឺ សហគមន៍កសិកម្មជាអង្គការដែលផ្តល់ផលប្រយោជន៍ដល់សមាជិកតាមរយៈមុខរបរ មិនមែនដើម្បីភាគលាភទេ ។

លើសពីនេះ មន្ត្រីរបស់សហគមន៍កសិកម្ម និងមន្ត្រីដែលទទួលបន្ទុកក្នុងការអភិវឌ្ឍន៍សហគមន៍កសិកម្មត្រូវយល់ឱ្យបានច្បាស់ថា សហគមន៍កសិកម្មមិនត្រូវផ្តល់មូលនិធិលើកទឹកចិត្តសមាជិក និងប្រាក់ភាគលាភទេប្រសិនបើសហគមន៍កសិកម្មមិនមានប្រាក់ចំណេញ សហគមន៍កសិកម្ម មិនត្រូវសន្យាពីប្រាក់ចំណេញរបស់ខ្លួននៅពេលអនាគតទេ ។ វាខុសគ្នាទាំងស្រុងរវាងការប្រាក់សម្រាប់ប្រាក់បញ្ញើរបស់សមាជិកនិងប្រាក់ភាគលាភ ។

### ២.៦. ប្រាក់ឧបត្ថម្ភសម្រាប់សមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ

(ដកដោយស្ម័គ្រចិត្ត ហើយភាគរយ (ចំនួនទឹកប្រាក់) ត្រូវសម្រេចក្នុងមហាសន្និបាត)

យោងតាមច្បាប់ស្តីពីសហគមន៍កសិកម្មនៅប្រទេសកម្ពុជា សមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យពុំមានប្រាក់បំណាច់ឡើយ ប៉ុន្តែមហាសន្និបាតអាចគ្រោងទុកនូវថវិកាសម្រាប់ទូទាត់ចំណាយលើការបំពេញការងារនិងប្រាក់ឧបត្ថម្ភជូនក្រុមប្រឹក្សាភិបាល និងគណៈកម្មាភិបាលត្រួតពិនិត្យបាន (មាត្រា ៥៣)។

ដូច្នេះ សហគមន៍កសិកម្ម គួរផ្តល់ជូនពួកគាត់ទៅតាមគុណភាព និងបរិមាណនៃសកម្មភាពការងាររបស់សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ ប្រសិនបើសហគមន៍កសិកម្មអាចទទួលរ៉ាប់រងបាន។ ចំនួនទឹកប្រាក់ដែលត្រូវផ្តល់ជូនត្រូវបានសម្រេចយល់ព្រមដោយសមាជិកភាគច្រើន ដោយពិចារណាទៅលើចំនួនប្រាក់ភាគលាភដែលបានផ្តល់ជូនសមាជិក និងចំនួនប្រាក់លើកទឹកចិត្តរបស់នាយកគ្រប់គ្រងដែលផ្តល់ជូនដោយអង្គការនានាដែលមានលក្ខណៈស្រដៀងគ្នានឹងសហគមន៍កសិកម្មដែរ ។

**Guideline on Allocation of Profit of Agricultural Cooperative in Cambodia**

Printed in August 2016

Published by Department of Agricultural Cooperative Promotion of General Directorate of Agriculture (MAFF)
The Project for Establishing Business Oriented Agricultural Cooperative Models (BPAC)

Address: #54B/49F.St395-656,Sangkat Toeuk Laak 3 Khan Tuol Kok, Phnom penh ,Cambodia,
Phone: (023) 883 427, Fax : (023) 883 427

© The Project for Establishing Business-Oriented Agricultural Cooperative Models

Supported by Japan International Cooperation Agency (JICA)